អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១០

# សេចក្តីអញ្ជើញចូលរួមក្នុងសវនាការរបស់អង្គបុរេជំនុំជម្រះនៃអ.វ.ត.ក

អង្គបុរេជំនុំជម្រះនៃអ.វ.ត.ក បានកំណត់ថ្ងៃបើកសវនាការសាធារណៈ ដើម្បីប្រកាសដីកាសម្រេចរបស់ខ្លួន លើបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹង ការបន្តថេរវេលាឃុំខ្លួនបណ្តោះអាសន្ន លើជនត្រូវចោទ អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ នាថ្ងៃសុក្រ ទី ៣០ ខែមេសា ឆ្នាំ២០១០ នាវេលាម៉ោង ៩ព្រឹក ។

សវនាការសាធារណៈទាំងបី ត្រូវបានកំណត់ដូចខាងក្រោមនេះ៖

ម៉ោង ៩:០០ ព្រឹក : សវនាការរបស់ អៀង សារី

ម៉ោង ១០: ៣០ ព្រឹក : សវនាការរបស់ ខៀវ សំផន

ម៉ោង ២:០០ រសៀល : សវនាការរបស់ អៀង ធីរិទ្ធ

សូមបញ្ជាក់ផងដែរថា អង្គបុរេជំនុំជម្រះ នៃអ.វ.ត.ក បានបើកសវនាការសាធារណៈ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងការបន្តថេរវេលាឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ អៀង សារី កាលពីថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០១០ ខៀវ សំផន កាលពីថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០១០ និងអៀង ធីរិទ្ធ កាលពីថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១០។

**សេចក្តីអញ្ជើញ:** សាធារណជនទូទៅ តំណាងប្រព័ន្ធសារព័ត៌មាននីមួយៗ តំណាងអង្គការក្រៅរដ្ឋាភិបាល អង្គទូត និងតំណាងរដ្ឋាភិបាល ត្រូវបានអញ្ជើញឲ្យចូលរួមដោយផ្ទាល់ នៅក្នុងសវនាការនោះ ។ អង្គបុរេជំនុំជម្រះបានសំរេច និងអនុញ្ញាតឲ្យមានការផ្សាយបន្តផ្ទាល់ពីដំណើរការសវនាការទៅដល់ស្ថានីយវិទ្យុនិងទូរទស្សន៍សំរាប់ផ្សព្វផ្សាយជាសាធារណៈ និងអនុញ្ញាតឲ្យអ្នកថតរូបមួយចំនួន ចូលថតដោយផ្ទាល់ក្នុងបន្ទប់សវនាការ។

អ្នកចូលរួមទាំងអស់ ត្រូវមានវត្តមាននៅកន្លែងអង្គុយដែលបំរុងទុករយៈពេល ៣០ នាទីមុនពេលសវនាការចាប់ផ្តើម ។ អ្នកចូលរួមទាំងអស់ តំរូវឲ្យមកដល់បរិវេណអ.វ.ត.កក្នុងចន្លោះពីម៉ោង ៧:៣០ ព្រឹកដល់ម៉ោង ៨:០០ព្រឹក ដើម្បីទុកពេលឲ្យសន្តិសុខធ្វើការត្រួតពិនិត្យនិងចេញប័ណ្ណ។ ក្លោងទ្វាមុខនឹងបិទនៅវេលាម៉ោង៨:៤៥ ព្រឹក ឬនៅពេលដែលកន្លែងអង្គុយនៅក្នុងសាលសវនាការពេញអស់។

អ្នកចូលរួមទាំងអស់ត្រូវបង្ហាញអត្តសញ្ញាណសំគាល់ដែលមានភ្ជាប់រូបថត ហើយត្រូវឆ្លងកាត់ការត្រួតពិនិត្យផែកឆេររបស់សន្តិសុខ។ សូមកត់សំគាល់ផងដែរថា បុគ្គលក្រោមអាយុ១៦ឆ្នាំ នឹងមិនអនុញ្ញាតិឲ្យចូលក្នុងសាល

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខ័ណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ ៧១
ទូរស័ព្ទលេខ + ៨៥៥ (០) ២៣ ២១៩ ៨១៤ ទូរសារលេខ + ៨៥៥ (០) ២៣ ២១៩ ៨៤១ Web: www.eccc.gov.kh

សវនាការនោះទេ។ ទូរស័ព្ទ កាបូបធំៗ ចំណីអាហារ និងភេសជ្ជៈ នឹងត្រូវហាមឃាត់មិនឲ្យនាំចូលក្នុងសាលសវនាការនោះទេ។

សាធារណៈជនទូទៅ ត្រូវបានលើកទឹកចិត្តក្នុងការចុះឈ្មោះជាមុន ហើយអ្នកដែលមកមុននឹងទទួលបាន កន្លែងអង្គុយមុន។ កន្លែងអង្គុយភាគច្រើន ក្នុងចំណោមកន្លែងអង្គុយទាំងអស់ចំនួន ៥០០ កន្លែង ត្រូវបានបំរុងទុកសំរាប់ដើមបណ្តឹងរដ្ឋប្បវេណី និង សាធារណៈជនទូទៅដែលត្រូវបានដឹកជញ្ជូនមកដោយសាលាក្តី និងកន្លែងអង្គុយមួយចំនួនទៀត ទុកសំរាប់អង្គការក្រៅរដ្ឋាភិបាល។

**មធ្យោបាយធ្វើដំណើរ** ៖ អ.វ.ត.ក នឹងផ្តល់ សេវាកម្មធ្វើដំណើរដោយឥតគិតថ្លៃសំរាប់អ្នកសារព័ត៏មាន ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណៈជន ដែលមិនមានមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនទាំងទៅនិងមកកាន់ អ.វ.ត.ក។ រថយន្តក្រុង នឹងចាកចេញពីមុខស្ថានីយរាជាយស្ម័យាន ពីចន្លោះម៉ោង ៧:៣០ព្រឹក ដល់ម៉ោង៨:០០ព្រឹក នៅរាល់ថ្ងៃសវនាការ។ សំរាប់អ្នកត្រូវការសេវាកម្មនេះ គឺទាមទារឲ្យមានការចុះឈ្មោះជាមុន។

អ.វ.ត.ក មានទីតាំងស្ថិតនៅសង្កាត់ចោមចៅ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញតាមបណ្តោយផ្លូវជាតិលេខ៤ ចំងាយប្រមាណ១៦គីឡូម៉ែត្រពីភ្នំពេញ គឺស្ថិតនៅខាងឆ្វេងដៃនៃផ្លូវជាតិលេខ៤។ សាធារណៈជន និងតំណាងសារព័ត៏មាននានា សូមអញ្ជើញចូលតាមច្រកទ្វាសំរាប់អ្នកចូលទស្សនា ដែលស្ថិតនៅប៉ែកខាងកើតនៃបរិវេណ អ.វ.ត.ក។

**ការសំរបសំរួលទូទៅ** ៖ ទឹកបរិសុទ្ធមានដាក់នៅផ្លូវចូលនៅខាងក្រៅសាលសវនាការ។ ភេសជ្ជៈ និងអាហារហាមនាំចូលក្នុងសាលសវនាការ។ កញ្ចប់បាយ ឬអាហារថ្ងៃត្រង់ អាចទិញបាននៅអាហារដ្ឋានទីនេះ។

បង្គន់អនាម័យមាន នៅក្នុងអាគារសវនាការ និងចំណតរថយន្ត។
ចំណតរថយន្ត មានបំរុងទុកសំរាប់អ្នកចូលរួមដែលប្រើមធ្យោបាយផ្ទាល់ខ្លួនរាប់ទាំងរថយន្តក្រុង និងរថយន្តតូច។ ជំនួយសំរាប់ជនពិការក៏មានផ្តល់ជូនផងដែរ រាប់បញ្ចូលទាំងកន្លែងអង្គុយរុញ។

ការចុះឈ្មោះសំរាប់សាធារណៈជនទូទៅ និងសេវាកម្មធ្វើដំណើរ សូមទាក់ទងមកកាន់ លោក **ជឹន ហេមវិចិត្រ**

ទូរសព្ទ័: (០២៣)២១៩ ៨១៤ លេខបន្ត:៦០៦៥
ទូរសព្ទ័ដៃ: (០១២) ៦៩៦ ២២០
ទូរសារ: (០២៣) ២១៩ ៨១៤ លេខបន្ត:៦០៦៩
អ៊ីម៉ែល: pas@eccc.gov.kh

សំរាប់ព័ត៌មានបន្ថែមនិងការសំរបសំរួលផ្សេងៗ  សូមមើលក្នុងសេចក្តីប្រកាសព័ត៌មានសំរាប់ប្រព័ន្ធផ្សព្វផ្សាយ ឬទាក់ទង លោក **ឌឹម សុវណ្ណារុំ**  តាមរយៈទូរស័ព្ទលេខ ០១២ ៤៨៨ ០៩៤ ឬ  លោក **ឡាស អូលសិន** តាមរយៈទូរស័ព្ទលេខ ០១២ ៤៨៨  ០២៣ ។


ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh